**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកណ្តាល**

សំណុំរឿងរដ្ឋប្បវេណីលេខ ៥០៤
ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២២
សាលក្រមលេខ:០១៦ "ធ"/២២
ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០២២

**ក្នុងនាមប្រជារាស្ត្រខ្មែរ**
**សាលាដំបូងខេត្តកណ្តាល**

បានបញ្ចប់នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់
នៅថ្ងៃទី១០ ខែតុលា ២០២២ និងប្រកាសសាលក្រមជាសាធារណៈ
នៅថ្ងៃទី១០ ខែតុលា ឆ្នាំ២០២២ លើសំណុំរឿងរដ្ឋប្បវេណីលេខ:៥០៤ ចុះថ្ងៃទី ២០ ខែមិថុនា ឆ្នាំ២០២២

**ដោយមានសមាសភាព**
**ចៅក្រមជំនុំជម្រះ**

លោក [redacted] ជាចៅក្រមសាលាដំបូងខេត្តកណ្តាល

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ជាក្រឡាបញ្ជីសាលាដំបូងខេត្តកណ្តាល

**ដើមចោទរវាង ៖**

ឈ្មោះ [redacted] ស៊ាងឡេង ភេទប្រុស អាយុ៣៦ ឆ្នាំ ជនជាតិខ្មែរ មុខរបររកស៊ី ទីលំនៅបច្ចុប្បន្ន [redacted] ។

មានលោក [redacted] ជាមេធាវីតំណាងដោយអាណត្តិ មានអាសយដ្ឋានក្រុមហ៊ុនមេធាវី [redacted] អាសយដ្ឋានផ្ទះលេខ [redacted] ។

**និងចុងចម្លើយ៖**

ឈ្មោះ [redacted] ណារី ភេទស្រី អាយុ៤១ ឆ្នាំ ជនជាតិខ្មែរ មុខរបររកស៊ី មានទីលំនៅបច្ចុប្បន្ន [redacted] ។

**អង្គហេតុ និងការអះអាងរបស់គូភាគី**

**ក. ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារ ៖**

១.សុំលែងលះពីចុងចម្លើយឈ្មោះ [redacted] ណារី។

២.ផ្តាច់ចំណងអាពាហ៍ពិពាហ៍ ដោយមានសំបុត្រអាពាហ៍ពិពាហ៍លេខ:០៩ ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ ២០០៧ ចេញដោយអគ្រានុកូលដ្ឋានឃុំកំពង់កុង ។

៣.សុំបែងចែកទ្រព្យសម្បត្តិរួមជាពីរចំណែកស្មើគ្នាតាមច្បាប់ ។

៤.សុំអំណាចមេបាលើកូនទាំងពីរនាក់មានឈ្មោះ [redacted] តាំងមួយ ភេទស្រី កើតថ្ងៃទី២១ ខែឧសភា ឆ្នាំ ២០០៨ និងកូនឈ្មោះ [redacted] តាំងជិញ ភេទប្រុស កើតថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១០ ។

**ខ. អង្គហេតុ និង ចំណុចវិវាទ**

ដើមចោទឈ្មោះ [redacted] ស៊ាងឡេង បានរៀបអាពាហ៍ពិពាហ៍ជាមួយចុងចម្លើយឈ្មោះ [redacted] ណារី តាមប្រពៃណីខ្មែរ និងបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់លេខ:០៩ ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០០៧ នៃសៀវភៅអាពាហ៍ពិពាហ៍លេខ:០១/២០០៧ ដែលចេញដោយអគ្រានុកូលដ្ឋានឃុំកំពង់កុង ស្រុកកោះធំ ខេត្តកណ្តាល។ នៅក្នុងចំណងអាពាហ៍ពិពាហ៍ដើមចោទ និងចុងចម្លើយមានកូនចំនួនពីរនាក់ក្នុងបន្ទុកមានឈ្មោះ

ក្រឡាបញ្ជី ស្រាវ រ៉ាវុធ

Scanned with CamScanner

[redacted]តាំងមួយ ភេទស្រី កើតថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៨ និងកូនឈ្មោះ [redacted] តាំងជិញ ភេទប្រុស កើតថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១០ និងមានទ្រព្យមួយចំនួនដែលត្រូវបែងចែក ហើយចំពោះបំណុលរួមគ្មាន។ ក្រោយពីរស់នៅជាមួយគ្នាជាប្តីប្រពន្ធតាំងពីឆ្នាំ២០០៧ រហូតមកដល់បច្ចុប្បន្ន ដើមចោទនិងចុងចម្លើយរស់នៅមិនចុះសម្រុងគ្នា មានរឿងមិនចេះចប់មិនចេះហើយ ហើយចុងចម្លើយបានយកទ្រព្យសម្បត្តិដែលខំរក យកទៅចុះចោលដើមចោទ។ ជាក់ស្តែងបច្ចុប្បន្ននេះ នៅខែមេសា ឆ្នាំ២០២១ ចុងចម្លើយឈ្មោះ [redacted] ណារី បាននាំយកកូនទៅជាមួយ រួមទាំងទ្រព្យសម្បត្តិរួមមួយចំនួន និងឯកសារថែមទៀត។ ដើមចោទបានព្យាយាមចចារជាមួយចុងចម្លើយជាច្រើនដងដែរ ប៉ុន្តែមិនទទួលបានលទ្ធផលទេ បែរជាចុងចម្លើយបានដេញដើមចោទឲ្យទៅដាក់ពាក្យបណ្តឹងថែមទៀត។ ទើបមកដល់ពេលនេះដើមចោទ បានដាក់ពាក្យបណ្តឹងសុំលែងលះពីចុងចម្លើយដោយសារការរស់នៅមិនចុះសម្រុងគ្នា និងអស់មនោសញ្ចេតនារស់នៅជាមួយគ្នាជាប្តីប្រពន្ធតទៅទៀត។ ហេតុដូចនេះ ខ្លួនសំណូមពរតុលាការចេញសាលក្រមលែងលះជាមួយចុងចម្លើយឈ្មោះ [redacted] ណារី និងសុំសិទ្ធិទ្រព្យសម្បត្តិដែលសុំបែងចែកមាន៖

-ម៉ូតូម៉ាក ZoomerX សេរីឆ្នាំ២០១៨ ពណ៌ក្រហមលាយខ្មៅ មានស្លាកលេខត្បូងឃ្មុំ1E-0203។

-ម៉ូតូម៉ាក ហុងដាគប់ជ្រុង ពណ៌ខៀវ។

-ប្រាក់ចំនួន USD៩.៣០០(ប្រាំបួនពាន់បីរយ) ដុល្លារអាមេរិក ដែលបានមកពីការលក់ដីចំការមួយកន្លែងស្ថិតនៅភូមិព្រែកផ្អាវ ឃុំកំពង់កុង ស្រុកកោះធំ ខេត្តកណ្តាល។

-ប្រាក់ចំនួន USD៤.៣០០(បួនពាន់) ដុល្លារអាមេរិក ដែលបានសន្សំមកពីការរកស៊ី។

-សុំសិទ្ធិអំណាចមេបាលើកូនទាំងពីរនាក់មានឈ្មោះ [redacted] តាំងមួយ ភេទស្រី កើតថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៨ និងកូនឈ្មោះ [redacted] តាំងជិញ ភេទប្រុស កើតថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១០។

ខ.ក.១ រឿងក្តីនេះដើមចោទបានធ្វើសេចក្តីថ្លែងការណ៍ថា: ដើមចោទឈ្មោះ [redacted] ស៊ាងឡេង មានលោក [redacted] ជាមេធាវីតំណាងឲ្យដើមចោទធ្វើសេចក្តីថ្លែងការណ៍ថា៖ ដើមចោទសូមរក្សានូវការទាមទារដូចមាន នៅក្នុងពាក្យបណ្តឹងចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២២ ,កំណត់ហេតុសាកសួរ ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២២ និងកំណត់ហេតុសាកសួរ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០២២ ទុកជាបានការដដែល។ ចំពោះឯកសារពាក់ព័ន្ធម៉ូតូទាំងពីរគ្រឿង មានម៉ាក Zoomer X សេរីឆ្នាំ២០១៨ ពណ៌ក្រហម លាយខ្មៅ ដែលមានស្លាកលេខត្បូងឃ្មុំ 1E-0203, ម៉ូតូម៉ាកហុងដាគុបជ្រុង ពណ៌ខៀវ , ប្រាក់ចំនួនUSD៩.៣០០ ស្ថិតនៅភូមិព្រែកផ្អាវ ឃុំកំពុងកុង ស្រុកកោះធំ ខេត្តកណ្តាល ដែលបានមកពីការលក់ដីនោះ គឺប្រាក់នោះបានឃើញជាក់ស្តែងទាំងអស់គ្នា និងប្រាក់ចំនួនUSD៤.០០០ ដែលបានមកពីការរកស៊ីរួមគ្នានោះ ដើមចោទមិនមានឯកសារទុកដាក់នឹងខ្លួនទេ គឺនៅខាងចុងចម្លើយជាអ្នកទុកដាក់ទាំងអស់។ ចំពោះអាហារកាតព្វកិច្ចដែលចុងចម្លើយសុំទាមទារផ្តាច់ចំនួនUSD៦.០០០ គឺខ្ញុំបាទសូមបដិសេធ ។

ខ.ក.២. រឿងក្តីនេះចុងចម្លើយឈ្មោះ [redacted] ណារី បានធ្វើសេចក្តីការណ៍ថា ៖ ចុងចម្លើយសូមរក្សាការទាមទារដូចមាននៅក្នុងកំណត់ហេតុ ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២២ និងកំណត់ហេតុ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០២២ ទុកជាបានការដដែល។ ចំពោះម៉ូតូ Zoomer X សេរីឆ្នាំ២០១៨ ពណ៌ក្រហម លាយខ្មៅ ដែលមានស្លាកលេខត្បូងឃ្មុំ 1E-0203, ម៉ូតូម៉ាកហុងដាគុបជ្រុង ពណ៌ខៀវ គឺឯកសារដែលមានកាតគ្រីម៉ូតូ ចុងចម្លើយជាអ្នកទុកដាក់។ រីឯប្រាក់ដែលបានមកពីការលក់ដី បានប្រាក់ចំនួនUSD៩.៣០០ ស្ថិតនៅភូមិព្រែកផ្អាវ ឃុំកំពុងកុង ស្រុកកោះធំ ខេត្តកណ្តាល គឺឪពុកចុងចម្លើយគាត់ជាអ្នកទិញពីមុន និងជាអ្នកលក់ខ្លួនគាត់ដែលមានតែឈ្មោះគាត់ទេអ្នកធ្វើ រហូតមកដល់ពេលនេះដោយសារគាត់ទទួលមរណភាព ទើបឯកសារទិញលក់នោះ គឺនៅលើចុងចម្លើយជាអ្នកទុកដាក់ទាំងអស់ ហើយប្រាក់ដែលបានមកពីការលក់ដីនោះ គឺចាត់ចែងមើលជំងឺគាត់ និង

ធ្វើបុណ្យគាត់អស់ហើយដែរ។ ចំពោះប្រាក់ចំនួនUSD៤.០០០ដែលដើមបណ្ដឹងបានអះអាង ថាបានមកពីការរកស៊ីរួមគ្នានោះ គឺប្រាក់នោះមានតែUSD៣.០០០ គឺចុងចម្លើយបានប្រើប្រាស់អស់ហើយ។ ចុងចម្លើយនៅតែរក្សាការទាមទារជាអ្នកមានសិទ្ធិអំណាចមេបាគ្រប់គ្រងកូនចំនួន០២ នាក់ និងសូមឲ្យគាត់បង់អាហារកាតព្វកិច្ចដោយសុំផ្ដាច់សរុបជាប្រាក់ចំនួនUSD៦.០០០ ដដែល រហូតដល់កូនមាននីតិភាព អាយុ១៨ ឆ្នាំ។

**ខ.ខ អង្គហេតុដែលគ្មានវិវាទ**

ដើមចោទឈ្មោះ [redacted] ស៊ាងឡេង បានរៀបអាពាហ៍ពិពាហ៍ជាមួយចុងចម្លើយឈ្មោះ [redacted] ណារី តាមប្រពៃណីខ្មែរ និងបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់លេខ:០៩ ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០០៧ នៃសៀវភៅអាពាហ៍ពិពាហ៍លេខ:០១ ២០០៧ ដែលចេញដោយអត្រានុកូលដ្ឋានឃុំកំពង់កុង/ស្រុកកោះធំ ខេត្តកណ្ដាល។ នៅក្នុងចំណងអាពាហ៍ពិពាហ៍ដើមចោទ និងចុងចម្លើយមានកូនចំនួនពីរនាក់ក្នុងបន្ទុកមានឈ្មោះ [redacted] តាំងមួយ ភេទស្រី កើតថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៨ និងកូនឈ្មោះ [redacted] តាំងជិញ ភេទប្រុស កើតថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១០។ ឯចំពោះទ្រព្យរួមដែលសុំបែងចែកមាន៖

-ម៉ូតូម៉ាក ZoomerX សេរីឆ្នាំ២០១៨ ពណ៌ក្រហមលាយខ្មៅ មានស្លាកលេខត្បូងឃ្មុំ1E-0203។

-ម៉ូតូម៉ាក ហុងដាគប់ជ្រុង ពណ៌ខៀវ។

-ប្រាក់ចំនួន USD៩.៣០០(ប្រាំបួនពាន់បីរយ) ដុល្លារអាមេរិក ដែលបានមកពីការលក់ដីចំការមួយកន្លែងស្ថិតនៅភូមិព្រែកផ្អាវ ឃុំកំពង់កុង ស្រុកកោះធំ ខេត្តកណ្ដាល។

-ប្រាក់ចំនួន USD៤.៣០០(បួនពាន់) ដុល្លារអាមេរិក ដែលបានសន្សំមកពីការរកស៊ី។

-សុំសិទ្ធិអំណាចមេបាលើកូនទាំងពីរនាក់មានឈ្មោះ [redacted] តាំងមួយ ភេទស្រី កើតថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៨ និងកូនឈ្មោះ [redacted] តាំងជិញ ភេទប្រុស កើតថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១០។

-បំណុលរួមគ្មាននោះទេ ។

**ខ.គ ចំណុចវិវាទ**

-តើដើមចោទឈ្មោះ [redacted] ស៊ាងឡេង ទាមទារលែងលះពីចុងចម្លើយឈ្មោះ [redacted] ណារី មានលក្ខណៈត្រឹមត្រូវតាមច្បាប់ដែរឬទេ ?

-តើដើមចោទឈ្មោះ [redacted] ស៊ាងឡេង ទាមទារបែងចែកទ្រព្យសម្បត្តិរួមជាពីរចំណែកស្មើគ្នាជាមួយចុងចម្លើយឈ្មោះ [redacted] ណារី មានលក្ខណៈត្រឹមត្រូវតាមច្បាប់ដែរឬទេ ?

-រវាងដើមចោទ និងចុងចម្លើយ តើអ្នកណាស័ក្តិសមជាអ្នកមានសិទ្ធិអំណាចមេបា ក្នុងការគ្រប់គ្រងលើកូនទាំងពីរអ្នកដែលមានឈ្មោះ [redacted] តាំងមួយ ភេទស្រី កើតថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៨ និងឈ្មោះ [redacted] តាំងជិញ ភេទប្រុស កើតថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១០?

## គ. ការពិនិត្យភស្តុតាង

- ឯកសារថតចម្លង នៃសំបុត្រអាពាហ៍ពិពាហ៍លេខ:០៩ ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០០៧ នៃសៀវភៅអាពាហ៍ពិពាហ៍លេខ:០១/២០០៧ ដែលចេញដោយមន្ត្រីអត្រានុកូលដ្ឋានឃុំកំពង់កុង ស្រុកកោះធំ ខេត្តកណ្ដាល។
- ឯកសារថតចម្លង នៃសំបុត្របញ្ជាក់កំណើតលេខ:៧១៨ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០៤ ដែលមាននៅក្នុងសៀវភៅបញ្ជាក់កំណើតលេខ:០៨ /២០០៤។
- ឯកសារថតចម្លង នៃសំបុត្របញ្ជាក់កំណើតលេខ:៣៦ ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០០៨ នៃសៀវភៅបញ្ជាក់កំណើតលេខ:០១/២០០៨ របស់ឈ្មោះ ឡេង តាំងមួយ ដែលចេញដោយរដ្ឋបាលឃុំកំពង់កុង ស្រុកកោះធំ ខេត្តកណ្ដាល។

ក្រឡាបញ្ជី ស្រស់ វាំង

Scanned with CamScanner

- ឯកសារថតចម្លង នៃសំបុត្របញ្ជាក់កំណើតលេខៈ៥០ ចុះថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១០ នៃសៀវភៅបញ្ជាក់កំណើតលេខៈ០២/២០១០ របស់ឈ្មោះ ឡេង តាំងជិញ ដែលចេញដោយរដ្ឋបាលឃុំកំពង់កុង ស្រុកកោះធំ ខេត្តកណ្តាល។

## សំអាងហេតុ

១. យោងតាមឯកសារចម្លងនៃសំបុត្រអាពាហ៍ពិពាហ៍លេខ ០៩ សៀវភៅអាពាហ៍ពិពាហ៍ លេខ០១/២០០៧ រវាងចុងចម្លើយឈ្មោះ [redacted] ស៊ាងឡេង និង ដើមចោទឈ្មោះ [redacted]ណារី អាចបញ្ជាក់បានថាដើមចោទនិងចុងចម្លើយជាសហព័ទ្ធនឹងគ្នាតាមផ្លូវច្បាប់ ។

២. តាមការអះអាងរបស់ដើមចោទបានបញ្ជាក់ថា៖ ក្រោយពីរស់នៅជាមួយគ្នាជាប្តីប្រពន្ធតាំងពីឆ្នាំ២០០៧ រហូតមកដល់បច្ចុប្បន្ន ដើមចោទនិងចុងចម្លើយរស់នៅមិនចុះសម្រុងគ្នា មានរឿងមិនចេះចប់មិនចេះហើយដែលជាហេតុនាំឲ្យអស់មនោសញ្ចេតនាក្នុងការរស់នៅជាមួយគ្នាជាប្តីប្រពន្ធតទៅទៀត ហើយចុងចម្លើយបានយកទ្រព្យសម្បត្តិដែលខំរកស៊ីជាមួយគ្នាចំនួនUSD៤.០០០ (បួនពាន់) ដុល្លារអាមេរិក យកទៅចុះចោលដើមចោទ និងចុងចម្លើយបានអះអាងថា ខ្លួនឯកភាពលែងលះតាមការទាមទារដូចនៅក្នុងពាក្យប្តឹងរបស់ដើមចោទ ដោយសារតែខ្លួនអស់មនោសញ្ចេតនារស់នៅជាមួយគ្នាជាប្តីប្រពន្ធតទៅទៀតដែរ ចំណែកទ្រព្យសម្បត្តិដែលខំរកស៊ីជាមួយគ្នានោះគឺខ្លួនបានចាយវាយតាមតម្រូវការ និងចិញ្ចឹម ទំនុកបំរុងឲ្យកូនៗរៀនសូត្រ បង់ថ្លៃសាលាអស់ហើយ។ ឃើញថាភាគីទាំងសងខាងបានយល់ព្រមគ្នាតាមការទាមទាររបស់ដើមចោទទាំងស្រុង ហើយទំនាក់ទំនងអាពាហ៍ពិពាហ៍ត្រូវបានបែកបាក់ និងមិនអាចធ្វើបដិទានឡើងវិញបានទេ ហើយទោះបីជាបន្តរស់នៅជាមួយគ្នាក៏មានតែភាពកាំរកូសក្នុងគ្រួសារ មិនមានសុភមង្គល និងអាចប៉ះពាល់ផ្លូវអារម្មណ៍ដល់កូនជាអនីតិជនដែលកំពុងស្ថិតនៅក្នុងវ័យកំពុងលូតលាស់ ដូចនេះតុលាការយល់ឃើញថា ការលែងលះជាជម្រើសដ៏ល្អសម្រាប់ភាគីទាំងសងខាងរួមជាមួយនឹងកូនទាំងពីរ ស្របតាមបញ្ញត្តិមាត្រា ៩៧៨ កថាខណ្ឌទី១ ចំណុច ង នៃក្រមរដ្ឋប្បវេណី ។

៣. តាមសេចក្តីចម្លងសំបុត្របញ្ជាក់កំណើតលេខៈ៣៦ ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០០៨ នៃសៀវភៅបញ្ជាក់កំណើតលេខៈ០១ របស់ឈ្មោះ [redacted] តាំងមួយ ២០០៨/ភេទស្រី កើតថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៨ និងសេចក្តីចម្លងសំបុត្របញ្ជាក់កំណើតលេខ ៥០ ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១០ នៃសៀវភៅបញ្ជាក់កំណើតលេខៈ០២/២០១០ របស់ឈ្មោះ[redacted]តាំងជិញ បញ្ជាក់ថា កូនទាំងពីរនាក់នេះ ពិតជាកូនបង្កើតរបស់ដើមចោទ និងចុងចម្លើយ ហើយស្ថិតក្នុងវ័យអនីតិជនប្រាកដមែន ។

៤. ចុងចម្លើយទាមទារឲ្យដើមចោទជាឪពុកបង់សោហ៊ុយអាហារកាតព្វកិច្ចចាំបាច់ សម្រាប់ចិញ្ចឹមកូនជាប្រាក់សរុបចំនួនUSD៦.០០០ (ប្រាំមួយពាន់ដុល្លារ) អាមេរិក គប្បីតុលាការពិចារណា លើការទាមទារនេះដោយពិនិត្យលើស្ថានភាពជាក់ស្តែងនៃជីវភាពរបស់ដើមចោទ ព្រោះអនីតិជនត្រូវការចំណាយ ផ្គត់ផ្គង់គ្រប់សព្វសារពើដើម្បីឱ្យលូតលាស់បានគ្រប់គ្រាន់ពេញលេញ គប្បីតុលាការសម្រេចឱ្យដើមចោទឈ្មោះ [redacted] ស៊ាងឡេង ជាឪពុកបង្កើតមានករណីយកិច្ចបង់អាហារកិច្ចឲ្យទៅកូនឈ្មោះ [redacted] តាំងមួយ ភេទស្រី កើតថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៨ និងឈ្មោះ [redacted] តាំងជិញ ភេទប្រុស កើតថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១០ សម្រាប់ចិញ្ចឹមបីបាច់កូនតាមគោលការណ៍សមធម៌ ស្របតាមបញ្ញត្តិមាត្រា១១៤០និងមាត្រា១១៤១ នៃក្រមរដ្ឋប្បវេណី ។

៥. ដើមចោទ និងចុងចម្លើយបានឯកភាពគ្នាប្រគល់សិទ្ធិអំណាចមេបាលើកូនទៅឲ្យចុងចម្លើយ គប្បីតុលាការសម្រេចពិចារណាតាមការព្រមព្រៀងរបស់ភាគី ប៉ុន្តែត្រូវទុកសិទ្ធិឲ្យដើមចោទក្នុងការចូលជួប និងប្រាស្រ័យទាក់ទងកូនៗ ដោយផ្អែកតាមបញ្ញត្តិមាត្រា១០៤០ នៃក្រមរដ្ឋប្បវេណី។



Scanned with CamScanner

៦. ការទាមទារបែងចែកទ្រព្យសម្បត្តិរួមរវាងដើមចោទ និងចុងចម្លើយ តុលាការពិនិត្យឃើញថាពុំមានឯកសារជាក់លាក់ រឹងមាំណាមួយដែលបញ្ជាក់ពីអត្ថិភាពនៃទ្រព្យសម្បត្តិទាំងនោះទេ គប្បីតុលាការច្រានចោលការទាមទារត្រង់ចំណុចនេះ។

៧. ផ្អែកតាមមាត្រា៦៤នៃក្រមនីតិវិធីរដ្ឋប្បវេណី ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ភាគីចាញ់ក្តី ។

**សេចក្តីសម្រេចបញ្ចប់**

១. ឱ្យដើមចោទឈ្មោះ [redacted] ស៊ាងឡេង និងចុងចម្លើយឈ្មោះ [redacted] ណារី ដែលមានសំបុត្រអាពាហ៍ពិពាហ៍លេខៈ០៩ ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០០៧ នៃសៀវភៅអាពាហ៍ពិពាហ៍លេខៈ០១/២០០៧ ចេញដោយមន្ត្រីអត្រានុកូលដ្ឋានឃុំកំពង់កុង ស្រុកកោះធំ ខេត្តកណ្តាល លែងលះគ្នា ។

២. ច្រានចោលការទាមទារសុំបែកចែងទ្រព្យសម្បត្តិរួមជាពីរចំណែកស្មើគ្នា។

៣. ប្រគល់សិទ្ធិអំណាចមេបាលើកូនឈ្មោះ [redacted] តាំងមួយ ភេទស្រី កើតថ្ងៃទី២១ ខែឧសភា ឆ្នាំ ២០០៨ និងឈ្មោះ [redacted] តាំងជិញ ភេទប្រុស កើតថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១០ ឲ្យទៅចុងចម្លើយជាអ្នកមានសិទ្ធិអំណាចមេបា។

៤. បង្គាប់ឲ្យភាគីដើមចោទឈ្មោះ [redacted] ស៊ាងឡេង ជាអ្នកបង់អាហារកាតព្វកិច្ចចំពោះកូនទាំងពីរនាក់តាមលទ្ធភាពចំនួន ២០ ម៉ឺនរៀល ក្នុងមួយខែៗ រហូតដល់កូនទទួលបាននីតិភាពគ្រប់អាយុ១៨ ឆ្នាំ។ ចំពោះភាគីដែលពុំមានសិទ្ធិអំណាចមេបាលើកូនមានសិទ្ធិ និងចូលជួបប្រាស្រ័យទាក់ទងតាមវិធីដូចខាងក្រោមៈ

- ចូលជួបកូនបាន២(ពីរ) ដងក្នុងមួយខែ ដោយម្តងៗមិនឲ្យលើសពី ២(ពីរ) ម៉ោង លើកលែងតែមានការអនុញ្ញាតពិសេស ពីអ្នកមានសិទ្ធិអំណាចមេបា។

-ចូលជួបកូននៅលំនៅដ្ឋានរបស់អ្នកមានសិទ្ធិអំណាចមេបា លើកលែងតែមានការអនុញ្ញាតពិសេសពីអ្នកមានសិទ្ធិអំណាចមេបា។

៥. ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងម្លើយ ។

សាលក្រមនេបានបញ្ចប់ការទាញហេតុផល ប្រកាសជាសាធារណៈនៅថ្ងៃទី១០ ខែតុលា ឆ្នាំ២០២២ ចំពោះមុខដើមចោទ និងចុងចម្លើយ។

ភាគីដែលមិនសុខចិត្តមានសិទ្ធិប្តឹងឧទ្ធរណ៍នឹងសាលក្រមនេះតាមការកំណត់របស់ច្បាប់៕

**ចៅក្រម**

ហត្ថលេខា និងត្រា[redacted]

---

"បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃច័ន្ទ១៥កើត ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស២៥៦៦

កណ្តាល, ថ្ងៃទី១០ ខែតុលា ឆ្នាំ២០២២

**ក្រឡាបញ្ជី**

[redacted]

បានឃើញ

**ចៅក្រមជំនុំជម្រះ**

[redacted]

ក្រឡាបញ្ជី ស្រាវ រ៉ាវុធ

Scanned with CamScanner